គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

**លេខាធិការដ្ឋាន**

លេខ...០៦៥..ឈឈ...../គ.ជ.អ.ប

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានីភ្នំពេញ, ថ្ងៃទី..០៤.. ខែមិថុនា ឆ្នាំ២០១១

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការជ្រើសរើសមន្ត្រីនៃកម្មវិធីចំណាយប្រតិបត្តិការអាទិភាព សម្រាប់អនុកម្មវិធីទី១ នៃផអ៣

## នាយកកម្មវិធីចំណាយប្រតិបត្តិការអាទិភាពសម្រាប់អនុវត្តកម្មវិធីជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី ២៧ មករា ឆ្នាំ២០០៩ ស្តីពីការបង្កើត និងការប្រព្រឹត្តរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥២១ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការតែងតាំងប្រធាន អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើត និងដាក់ឱ្យអនុវត្តចំណាយប្រតិបត្តិការអាទិភាពក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ

- បានឃើញចេក្តីសម្រេចលេខ០០៧ សសរ/គ.ជ.អ.ប ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមការងារដឹកនាំកម្មវិធីចំណាយប្រតិបត្តិការអាទិភាព ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍនៃគម្រោងគាំទ្រផែនការអនុវត្តរយៈពេល៣ឆ្នាំនៃកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងឯកសារផែនការអនុវត្តរយៈពេល៣ឆ្នាំ២០១១-២០១៣នៃកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃផអ៣
- យោងចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១លើសំណើសុំអនុវត្តកម្មវិធីចំណាយប្រតិបត្តិការអាទិភាពសម្រាប់អនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១

## សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មការជ្រើសរើសមន្ត្រីចំណាយប្រតិបត្តិការអាទិភាព សម្រាប់អនុវត្តអនុកម្មវិធីទី១នៃផែនការអនុវត្តរយៈពេល៣ឆ្នាំរបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**ប្រការ ២.-**

គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ថាន់ ចំរើន** | អគ្គនាយករង នាយករងកម្មវិធី | ប្រធាន |
| ២. | លោក **ចាន់ សុធា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៣. | លោក **ស គិនីរ៉ា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៤. | លោក **សូ មុន្នីរក្សា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. | លោក **នី គីមសាន** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. | កញ្ញា **ទេ ស្រីមុំ** | មន្ត្រីនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | សមាជិក |
| ៧. | កញ្ញា **ផាន់ សុគន្ធា** | មន្ត្រីគ្រប់គ្រងបុគ្គលិកនៃលេខាធិការដ្ឋាន គ.ជ.អ.ប | សមាជិក |

**ប្រការ ២.-**

គណៈកម្មការជ្រើសរើសមន្ត្រីកម្មវិធីចំណាយប្រតិបត្តិការអាទិភាព សម្រាប់អនុវត្តអនុកម្មវិធីទី១នៃផែនការអនុវត្តរយៈពេល៣ឆ្នាំមានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- រៀបចំល័ក្ខខ័ណ្ឌការងារនៃមុខតំណែងដែលត្រូវជ្រើសរើស

- កំណត់លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស
- រៀបចំបញ្ជីសំណួរសម្រាប់ជ្រើសរើសបេក្ខជន
- ពិនិត្យវាយតម្លៃពាក្យសុំបំរើការងាររបស់បេក្ខជន និងរៀបចំជាបញ្ជីខ្លី (Shortlist)
- ជូនដំណឹងដល់បេក្ខជនដែលនឹងត្រូវធ្វើការសម្ភាសន៍ជ្រើសរើស
- រៀបចំកម្មវិធីសម្ភាសន៍ជ្រើសរើស និងធ្វើការជ្រើសរើស
- រៀបចំរបាយការណ៍អំពីលទ្ធផលនៃការជ្រើសរើស ដើម្បីដាក់ជូនប្រធានស្ថាប័នពិនិត្យ និងឯកភាព
- ត្រូវរៀបចំរបាយការណ៍អំពីលទ្ធផលនៃការជ្រើសរើស ដើម្បីផ្ញើជូននាយកកម្មវិធី
- បំពេញភារកិច្ចផ្សេងទៀតតាមការណែនាំរបស់នាយកកម្មវិធី ។

**ប្រការ ៤.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥.-**

ក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី១នៃលេខាធិការដ្ឋានគ.ជ.អ.ប និងអ្នកពាក់ព័ន្ធនានាត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**
**និងជានាយកកម្មវិធី**

សក់ សេដ្ឋា

**ចម្លងជូន :**

- ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដៃគូអភិវឌ្ឍន៍ជអព
- ដូចប្រការ២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ